- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនិងចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីកម្ពុជា នៃបណ្តាប្រទេសផ្តល់ជំនួយ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## សេចក្តីសំរេចលេខ ១៦ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែក
### នាំចេញនៃកម្មសិទ្ធិបញ្ញា

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងកិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ប្រធាន
- ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អនុប្រធាន
- ឯកឧត្តម តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម តំណាង ក្រសួងពត៌មាន សមាជិក

**ប្រការ ២ :** គណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា មានភារកិច្ចដូចតទៅ ៖

- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់នានា ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក និងកិច្ចព្រមព្រៀងនានា រវាងព្រះរាជាណាចក្រកម្ពុជា និងបណ្តាប្រទេសនៃសមាគមអាស៊ាន។
- សំរបសំរួលអោយមានភាពរលូនលើភារកិច្ចការងារ ដែលទាក់ទិនដល់កម្មសិទ្ធិបញ្ញា រវាងក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពត៌មាន និង ក្រសួងស្ថាប័នផ្សេងៗទៀត ដែលមានការពាក់ព័ន្ធ ។
- សំរបសំរួល និង ទទួលជំនួយនានាពីសហគមន៍អន្តរជាតិ លើវិស័យកម្មសិទ្ធិបញ្ញា ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល តាមតំណាក់កាលនីមួយៗ ។

**ប្រការ ៣ :** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយ សំរាប់ជួយការងារដែលមានសមាសភាពដូចខាងក្រោម :

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាន
- តំណាង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល សមាជិក
- តំណាង ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាង ក្រសួង ពត៌មាន សមាជិក

លេខាធិការដ្ឋាននេះ មានទីតាំង និងប្រើប្រាស់មន្ត្រីជំនួយការមួយចំនួនទៀត តាមការចាំបាច់ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤ :** សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីសំរួលការងារ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ

នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ១ និង ប្រការ៣ ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ៣-សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩

### សារាចរលេខ ០៣ សរ

### ស្ដីពីការពង្រឹងកិច្ចការពារសន្តិសុខ និង សណ្ដាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

***

ក្រោយពីការបោះឆ្នោតជាសកលប្រកបដោយជោគជ័យនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះ ការងារពង្រឹងកិច្ចការពារសន្តិសុខ និង សណ្ដាប់ធ្នាប់សាធារណៈ ធានាបានក្នុងការបំរើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ រួមចំណែកដល់កិច្ចការពារប្រទេសជាតិ ការពារសមិទ្ធផល នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ការពាររដ្ឋធម្មនុញ្ញ និងសមិទ្ធផលនានា ដែលប្រសូត្រចេញពីលទ្ធផល នៃការបោះឆ្នោតថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ។

ក្នុងការអនុវត្តន៍បេសកកម្មដ៏ឧត្តុង្គឧត្តមនេះ រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវចំណុចអសកម្មមួយចំនួនជុំវិញការងារនេះដែលសំខាន់ គឺមិនទាន់ក្លាយទៅជាចលនាភ្ញាក់រលឹកសហការព្រមៗ គ្នារវាងភ្នាក់ងារសន្តិសុខសណ្ដាប់ធ្នាប់ មន្ត្រីរាជការ និង ប្រជារាស្ត្រនៅឡើយ ដូចជាអំពើចាក់ប្លន់ប្រដាប់អាវុធ ការធ្វើមនុស្សឃាត ការចាប់ជំរិតទារប្រាក់ ការលួចឆក់ ការលួចវត្ថុបុរាណ ការលក់ដូរសំភារៈបរិក្ខារសឹក ការប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ ការគ្រប់គ្រងយានយន្តគ្រប់ប្រភេទលើផ្លូវសាធារណៈ ការបង្ការគ្រោះថ្នាក់អគ្គីភ័យ ការគ្រប់គ្រងស្ថិតិប្រជារាស្ត្រមិនទាន់បានច្បាស់លាស់ ការទប់ស្កាត់សំណង់អនាធិបតេយ្យ ការបង្កើតរបនល្បែងស៊ីសងខុសច្បាប់ ពេស្យាចារ ការជួញដូរស្ត្រី និង កុមារក្រុមជនពាលអាវ៉ាសែ ការផ្សព្វផ្សាយវប្បធម៌អាសអាភាស ការរត់ពន្ធគ្រឿងញៀន ចរាចរប្រាក់ក្លែងក្លាយ ការលេងល្បែងក្រខ្វក់ និង ការលក់ដូរគ្រឿងស្រវឹង មានជាតិពុល ការថែរក្សាអនាម័យសាធារណៈ ។ល។ ហេតុបច្ច័យទាំងអស់នេះហើយដែលជះឥទ្ធិពលមិនល្អដល់សន្តិសុខសាធារណៈ ដល់ផ្លូវចិត្ត និង ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ពិសេសនៅរាជធានីភ្នំពេញ និង ខេត្ត - ក្រុង មួយចំនួន ។ ដោយឡែកក៏នៅមានប្រភេទជនឱកាសនិយមមួយក្ដាប់តូច ដែលមានគិតដល់ផលប្រយោជន៍ជាតិជាធំ មិនគិតពីភាពក្រីក្រខ្វះខាតរបស់ប្រជារាស្ត្រ បានញុះញង់ឆ្លៀតឱកាស